# ការសម្ភាសរបស់ឈ្មោះ លោកយាយ ហាស អ៊ុម

កៈ អ្នកសម្ភាស ហេង សុជីវី ខៈអ្នកត្រូវបានគេសម្ភាសឈ្មោះ លូង យើម

កៈ បាទនៅថ្ងៃនេះគឺ ថ្ងៃទីមួយម្ភៃប្រាំបីខែវិច្ឆិការឆ្នាំពីរពាន់ប្រាំបួន ឥឡូវនេះខ្ញុំនៅភូមិក័រហាលស្រុកពាមឯក ខេត្តបាត់ដំបង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ហើយខ្ញុំនឹងសម្ភាសទៅកាន់អ៊ីស្រីម្នាក់ ហើយបច្ចុបន្នគាត់នៅភូមិនេះតែម្តង បាទជាតំបងខ្ញុំបាទសំស្គាល់ឈ្មោះអ៊ីស្រី ឈ្មោះពេញ នាមត្រកូលឈ្មោះអីដែរ?
ខៈ លូងយើម។
កៈ អ៊ីស្រីមានឈ្មោះហៅក្រៅទេ?
ខៈ ហៅតែអញ្ចឹងរហូត
កៈ ហើយកាលពីអ៊ីស្រីនៅពីក្មេង តើអ៊ីស្រីមានឈ្មោះអីដែរ?
ខៈ ឈ្មោះហ្នឹងឯងឈ្មោះតារហូតឯង គេហៅថាអញ្ចឹងចាប់ខ្ញុំធំដឹងក្តីមក។
កៈ បាទៗ អញ្ចឹង ទាក់ទងនឹងភាសាវិញ តើអ៊ីស្រីអាចនិយាយក្រៅពីភាសារខ្មែរ អាចនិយាយអីបានខ្លះ។
ខៈ អត់ចេះ មានតែខ្មែរ។
កៈ ភាសារខ្មែរអាចអានបាន សរសេរបានទេ?
ខៈ មិនសយវបានទេ ថាលូងបណ្តោយ កាលណោះថ្នាក់ទីបី ទីបួននោះ។
កៈ អញ្ចឹងទាក់ទងនឹងស្រុកកំណើតរបស់អ៊ីស្រី អ៊ីស្រី កើតនៅភូមិណា ឃុំណាស្រុកណា ខេត្តណាដែរ?
ខៈ ខ្ញុំកើតនៅនេះ ភូមិករហាល ឃុំពាមឯក ភូមិពាមឯង ខេត្តបាត់ដំបង។
កៈ ហើយបច្ចុប្បន្នអ៊ីស្រីមានអាយុ ប៉ុន្មានហើយ?
ខៈ ហាបួន។
កៈ បើយើងគិតជាឆ្នាំ ខ្មែរ គេហៅឆ្នាំអីគេ។
ខៈ ដូចជាឆ្នាំ ម្សាញ់ ចាំថាខែ ភទ្របុត។
កៈ អញ្ចឹងទាក់ទងនឹង រឿងអាពាហ៍ ពិពាហ៍វិញម្តង អ៊ុស្រីបានរៀបអាពាហ៍ ពិពាហ៍រយៈពេល ប៉ុន្មានឆ្នាំហើយ?
ខៈ តាំងពីអាយុម្ភៃប្រាំមក។
កៈ តើអ៊ីស្រី អ្នកណាជាអ្នករៀបចំអាពាហ៍ហ្នឹងអោយ?
ខៈ មីងមាបងប្អូន ចាស។
កៈ ចុះឪពុកម្តាយមានរៀបចំអោយទេ?
ខៈ អត់ ស្លាប់អស់ហើយ ស្លាប់តាំងពីនូវតូចៗ។
កៈ កាលរៀបអាពាហ៍ ពិពាហ៍គេយកបណ្ណាការប៉ុន្មានអ៊ីស្រី?
ខៈ តិចតួចដែរទេ ម៉ាជំនាន់នោះ ថោកដែរ បីបួនពាន់ បីបួនពាន់បាទ អញ្ចឹងណាស់។
កៈ បីបួនពាន់បាទ ឥឡូវប៉ុន្មាន?
ខៈ មិនដឹងប៉ុន្មានទេ កាលពីនៅកាលណោះថ្លៃដែរ យើងវាបានគ្នា កំព្រៀកំព្រាដូចគ្នាអញ្ចឹងណា។
កៈ សំនួរសួរថា ចុះហេតុអ្វីបានជាអ៊ីស្រី មានបំណងចង់រៀបការជាមួយអ៊ីប្រុស?
ខៈ អាហ្នឹងថា យើងទីទាល់គាឯង ចាស់ៗ ចាប់រៀបកា ផ្សំផ្គុំអោយទៅណាស់ ទិទាល់ថានៅម្នាក់ឯង គាគេលគាគោល នៅជុំរុំណោះ ពីដើមទៅនូវស្រុកគេ ទៅមើលពុកដល់ពេលពុកស្លាប់ទៅ ខ្ញុំវិលមកវិញបានប្តីបានអីទៅ បានមកនេះវិញ។
កៈ អ៊ីស្រីផ្ទាល់ អ៊ីស្រីពេញចិត្តអ៊ីប្រុសត្រង់ណា ត្រង់ចំណុចណា គាត់ជាមនុស្សមេចដែរ?

ខៈ គាតជាមនុស្សធម្មតាៗ ដូចគេ ហើយគាត់ស្រណោះអាណិត
កំព្រាកំព្រាអញ្ចឹងទៅ ប៉ណ្ណឹងគ្មានកាងាររអីទៀតទេតែប៉ុណ្ណឹង
នឹកឃើញថាគាត់ចង់យកយើងធ្វើអនាគត់ ចិញ្ចឹមយើង បើយើងកំព្រាកំព្រា
ហើយណាមួយគាត់ក៏កំព្រាដែរ អត់ម៉ែអត់ឪ ចង់អោយមនអានាគត
កំអោយគាគេ គាគោលប៉ុណ្ណឹង។
កៈ បាទ ថា ពេញចិត្តគាត់ត្រង់លក្ខណៈអាណិតគាត់។
ខៈ ចាស អាណិតគាត់ ត្រង់កំព្រាដូចគ្នា អត់ម្ដាយ អត់ឪពុកដូចគ្នា
ចាស់ៗទុកដាក់អោយ កំព្រមព្រៀងគ្នាទៅ ធ្វើតាមគាត់ចាស់ៗ ទៅណាស់
ដល់បានសុខទល់សព្វថ្ងៃទៅ បានកូនបានចៅ ប្រប្រិក ប្រើក។
កៈ អញ្ចឹងខ្ញុំសូមជម្រាបសួរទាក់ទង នឹងគ្រុមគ្រួសារវិញម្ដង
តើអ៊ីស្រីជាកូនទីប៉ុន្មានដែរ?
ខៈ កូនទីប្រាំមួយអញ្ចឹងឯង។
បាត់សំលេង
កៈ បាទ អរគុណដែលបានចែកចាយខ្ញុំទាក់ទងនឹងជីដូនជីតាទាំងខាងឪពុក
ទាំងខាងម្ដាយ
អញ្ចឹងខ្ញុំចង់សួរមួយទៀតទាក់ទងនឹងបងប្អូនដែលរស់នៅក្រៅប្រទេស
តអ៊ីស្រីមានបងប្អូន ឬសាច់ញ្ញាតិណាដែលរស់នៅក្រៅប្រទេសទេ?
ខៈ អត់អ៉ដែលមានទេ មាននៅតែនេះទាំងអស់ហ្នឹង។
កៈ អញ្ចឹងមានសាច់ញ្ញាតិ ឬក៏នរណាម្នាក់ទេ ដែលរស់នូវក្រៅប្រទេស ជប៉ុន កូរេ
ឬក៏សហរដ្ឋអាមេរិចអីហ្នឹង។
ខៈ រាល់ងៃប់រកស៊ីនៅថៃមាន។
កៈ កាត់រកស៊ីនៅថៃ គាត់ទៅប៉ុន្មានឆ្នាំហើយ?
ខៈ ទៅប្រហែលជាជិតដប់ឆ្នាំ ហើយខ្ញុំ។
កៈ កាត់ទៅធ្វើការអីដែរ?
ខៈ គាត់នៅខាងលក់ម្ហូបលក់បាយ ក្នុងស្រុកថៃ។
កៈ អញ្ចឹងគាត់លក់បាយម្ហូបនៅប្រទេសថៃ?
ខៈ ចាស។
កៈ គាត់មានគ្រួសារ ហើយនូវ?
ខៈ ដូចមានកូនមួយហាយ ញូរួសារមានកូនមួយហើយ។
កៈ ហើយគាត់ទៅតែឯង ឬទៅជាមួយគ្រួសារ?
ខៈ ទៅតែម្នាក់ឯង ចាស នៅកំព្រាកាលនោះ កូនកំព្រា។
កៈ អញ្ចឹងប្រពន្ធរបស់គាត់?
ខៈ លេងលះគ្នាតាំងពីក្មេង ប្ដីរកស៊ីចិញ្ចឹមកូន។
កៈ នៅសល់កូន មួយណោះ?
ខៈ ចាស នៅកូនមួយ។
កៈ អញ្ចឹងយើងបន្តទៀត ទសក់ទងនឹងក្រុមគ្រួសាររបស់ របស់អ៊ីស្រីផ្ទាល់
អ៊ីស្រីបច្ចុប្បន្នមានកូន ប៉ុន្មានអ្នក?
ខៈ ខ្ញុំមានកូនបួននាក់?
កៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?
ខៈ ប្រុសពីរ ស្រីពីរ។
កៈ កូនទីមួយគាត់ឈ្មោះអី?
ខៈ ឈ្មោះ ដួងសុខា។
កៈ គាត់កើតនៅណា?
ខៈ កើតនូវនេះឯង។
កៈ បច្ចុប្បន្នគាត់ធ្វើអ្វីដែរ?
ខ ៖ គាត់អត់ធ្វើអី ធ្វើការងារសំណង់តាមរោងចក្រ។
ក ៖ កូនទីពីរគាត់ឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះ ចាន្ថា ឈ្មោះ ដួង ចន្ថា។
ក៖ បាទ ហើយគាត់ កើយនៅឯណា?
ខ៖ កើតនូវនេះដែរ ដូចគ្នា។
ក៖ ថាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេ?
ខ៖ ភ្លេចអស់ហើយ ដឹងតែឆ្នាំរក ចាស ភ្លេចខែ ភ្លេចឆ្នាំកូនហើយ។
ក៖  អាយុគាត់ប៉ុន្មានហើយ?
ខ៖ អាយុជិតសាម សាមហើយកូននោះ។
ក៖ បច្ចុប្បន្នគាត់ធ្វើធីដែរ?
ខ៖ គាត់ទៅថៃហ្នឹងឯង។
ក៖ ទៅថៃកូនទីពីរ ចុះកូនទីបីឈ្មោះអ្វីដែរ?
ខ៖ កូនទីបីមួយមេញ។
ក៖ ឈ្មោះអួងសុខា។
ក៖ គាត់ធ្វើអ្វីដែរ?
ខ៖ អត់ធ្វើអីមើលតែកូន មើលតែចៅ។
ក៖ មេផ្ទះ?
ខ៖ មេផ្ទះ។
ក៖ ចុះកូនទីបួនឈ្មោះអី?
ខ៖ ឈ្មោះ ដួង វ៉ាឃីម។
ក៖ ដួងវ៉ាឃឹម កើតនៅស្រុកណាដែរ?
ខ៖ ស្រុកនេះឯង ចាស។
ក៖ បច្ចុប្បន្នគាតធ្វើអីដែរ?
ខ៖ សាងសង់។
ក៖ ខាងសំណង់?
ខ៖ ខាងក៏សាង ចាស។
ក៖ អញ្ចឹងទាក់ទងនឹងកូនខ្ញុំបានជម្រាបសួរហើយ
អញ្ចឹងខ្ញុំសូមជម្រាបសួរមួយទៀតទាក់ទងទៅប្តីរបស់អ៊ីស្រីវិញម្តង
ប្តីរបស់អ៊ីស្រីនោះណាស់ ប្តីរបស់អ៊ីស្រីគាត់ឈ្មោះអីដែរ?
ខ៖ ឈ្មោះ ដួងសុខុម គាត់ប្រកបមុខរបរបច្ចុប្បន្នអ្វីដែរ?
ក៖ ក៏សាងដែរ។
ក៖ អញ្ចឹងក្រៅពី ការក៏សាង ឬការសាងសង់ គាត់មានធ្វើអីទៀតទេ?
ខ៖ អត់មានផង ពីដើមគាត់ធ្វើស្រែ ឥឡូវសម្រាកធ្វើស្រែ
នៅតែខាងក៏សាងមួយមុខ។
ក៖ កាលពីក្មេងប្តីអ៊ីស្រីធ្វើអ្វីដែរ?
ខ៖ ធ្វើតែស្រែ ក៏សាងរហូត តាំងពិចាប់ដៃបានគ្នាមក គាត់ធ្វើតែក៏សាង។
ក៖ ហើយគាត់ជាមនុស្សមេចដែរ លក្ខណៈរបស់គាត់?
ខ៖ គាក់មានអី គាត់ធម្មតាៗ គាត់ជាមនុស្សសមញ្ញដែរ។
ក៖ ទាក់តងនឹង រូបរាងរបស់គាត់ស្គូម ឬក៏មិនស្គម ធាត់ក៏មិនធាត់ប៉ុន្មាន
ឡាតមនុស្សកណ្តាល។
ក៖ ខ្ពស់ទេ?
ខ៖ ខ្ពស់ក៏មិនខ្ពស់ប៉ុន្មាន។
ក៖ សក់របស់កាត់មេចដែរ?
ខ៖ សក់រាងរួញៗ ខោអងាវធម្មតាៗ មិនមានម៉ាកអីនឹងគេទេស្រខៀងស្រខួង
ចេះតែទៅហើយ វ័យសម្រាបមនុស្សចាស់។
ក៖ ទាក់ទងនឹងម្ហូបគាត់ចូលចិត្តម្ហូបអីដែរ?
ខ៖ ម្ហូបគាត់ចូលចិត្តសម្លរប្រហើរខ្លាំងចូលចិត្ត
និយាយអោយចំគាត់ចូលចិត្តណាស់ខាងនោះ ក្រៅពីនោះស្អីក៏បានដែរ
ចូលចិត្តជាងគេគឺមុខនោះឯង។

កៈ ហើយគាត់ចូលចិត្តធ្វើម្ហូបទេ?
ខៈ គាត់មិនចេះធ្វើទេ គាត់ចូលចិត្តតែអញ្ចឹង
ចូលចង្ក្រានគាត់មិនសូវចេះចូលទេ ព្រោះគាត់ជាប់រវល់ការងារគាត់។
កៈ ចុះទាក់ទងនឹងចំរៀងវិញគាត់ចូលចិត្តចម្រៀងទេ?
ខៈ អត់ទេ ចេះតែស្តាប់តែមិន ចេះច្រៀងចេះអីទេ។
កៈ បាទ ភាគច្រើនគាត់ចូលចិត្តចម្រៀងសម័យ ឬក៏បុរាណ?
ខ ៈ ចូលចិត្តបុរាណ បុរាណ ចូលចិត្តបុរាណ សម័យមិនសូវមានពេលស្តាប់
ព្រលឹមឡើងចេញព្រលប់ ឡើងចូល។
កៈ បាទ អម្បាញ់មិញខ្ញុំសួរទាក់ទង នឹងស្វាមីរបស់អ៊ុំស្រី ឥឡូវ
បច្ចុប្បន្នខ្ញុំសួរទាក់ទងនឹងអ៊ុំស្រីផ្ទាល់ម្តង អ៊ុំស្រីកាលពីតូច
អ៊ុំស្រីរៀននៅសាលាណាដែរ?
ខៈ នៅសាលាវត្តឯកយើងនេះ។
កៈ អ៊ុំស្រីរៀនបានប៉ុន្មានដែរ?
ខៈ រៀនបានថ្នាក់ទីបួន រៀនបានថ្នាក់ទីបួន
ឪពុកឈឺក៏យកឪពុកទៅមើលតែម្តង
អត់បានរៀនតាំងពីហ្នឹងរហូតដល់ឪពុកស្លាប់ហើយក៏នៅ ជំរុំទៅ
ចេញពីជំរុំមកនៅឯណេះវិញ កូនចៅនៅឯណេះ ចាស មានបានរៀនតអី
អាឡៃតែឪពុកឈឺ មើលឪពុក តាំងពីនោះមកក៏បានប្តីបានសីអី។
កៈ អញ្ចឹងបច្ចុប្បន្ននេះ អ៊ុំស្រីធ្វើការងារអីដែរ ឬក៏នៅតែផ្ទះ?
ខៈ ធ្វើស្រែ មកពីធ្វើស្រែនៅផ្ទះ ចេញពីនៅផ្ទះធ្វើស្រែ មកដាំបាយដាំអីទៅ។
កៈ អ៊ុំស្រីជួយរៀបរាប់បានទេ តាំងពីក្មេងរហូតដល់បច្ចុបន្ននេះ
តើជីវិតរបស់អ៊ុំស្រីមានការខុសប្លែកពីគ្នាយ៉ាងមេចដែរ?
ខៈ ខុសប្លែកត្រង់ថានៅពីក្មេងយើងមិនសូវនឿយមិនសូវហត់អីទេ ដល់មានប្តី
មានកូនមានចៅទៅវាហត់លំបាកមែន អញ្ចឹងទៅពិបាកវេទនា អាណាមើលចៅ
អាណា ម្ុះូបបាយសម្លរប្តី ព្រឹកល្ងាចទៅ។
កៈ អ៊ុំស្រីចាំបានទេ នៅក្នុងជីត្តអ៊ុំស្រីមានពេលណា ដែលពិបាកខ្លាំងជាងគេ
ពិបាករហូតដល់ដោះស្រាយមិនចង់ចេញ?
ខ ៈ ពេលលំបាកខ្លាំង ពេលណាដែលកូននិយាយស្តាប់បាន យើងមិនសូវអី
ដល់ពេលគេតម៉ាត់ តក៏ទៅពិបាកខ្លាំងមែនទែន ពិបាកត្រង់កន្លែងត្រង់ហ្នឹង
នឹកឃើញខំចិញ្ចឹមធំៗហើយ ពេលដែលតម៉ាត់តករខឹង មានចិត្តខឹងម្តងៗ
លំបាកស្ទើតែទ្រាំមិនបាន អស់យោបល់ហើយមានតែប៉ុណ្ណឹង ថាមិនអោយទៅ
នេះទៅណោះដូចនេះហើយមានចិត្តខឹង អត់មានជ្រុសជ្រុះយ៉ាងណាទេ
មានចិត្តកំហឹង មួយឆាំៗប៉ុណ្ណឹងឯង ប៉ុន្តែនៅក្នុងទប់បាន ក្មេងវាមិនដឹងអីណា។
កៈ អញ្ចឹងវិធីដោះស្រាយគឺ ទីមួយអ៊ុំស្រីមានការអត់ធ្មត់
ដើម្បីអោយឈប់ខឹងតើអ៊ុំស្រីធ្វើមេចខ្លះ?
ខ ៈ ទាញចិត្តនឹកថាក្មេងមិនដឹងអីទេ នឹកឃើញគ្នាចង់សប្បាយចង់ដែរ
ក៏ទាញចិត្តមកវិញទៅ ត្រជាក់ចិត្តពេលហឹងមក ឈប់ខឹងឈប់រករឿងទៅ ហឹៗ
ប្រដែប្រដៅអោយល្អៗ កូនស្តាប់វិញហើយ សប្បាយចិត្តមកវិញ ពិបាកដែរម្តងៗ
ដល់ឥឡូវកូនធំវិញអស់ទៅ។
កៈ បាទ ទាក់ទងនឹងម្ហូបវិញអ៊ុំរៀនចំអិនម្ហូបពីណាមក?
ខៈ ចំអិនពីបងប្អូនពីម៉ែពីឪមក ឃើញគាត់ដាំស្លរ
ពេលគាត់ដាំយើងអង្គុយមើលបន្តិចទៅ បន្តៗទៅ
ទាក់ទងនឹងម្ហូបអ៊ុំស្រីចេះធ្វើម្ហូបអីខ្លះ? ស្លរកកូរ ស្លរប្រហើរ ស្លរម្ជូរ ស្ងោរ អីផ្សេងៗ
អញ្ចឹងទៅ ចេះបានល្មមម៉ាហូបបាន ក្រៅពីនេះ ធំៗពេកអត់ចេះទេ
មិនដែរជួបប្រទះមិនចេះដែរ។

ក៖ ទាក់ទងនឹង គ្រៀមគ្រោះចេះអីខ្លះ? គ្រៀមគ្រោះមានតែចៀន
មានតែអាំងអីប៉ុណ្ណោះឯង ហូបប្រឡាក់ចៀនសាច់ ចៀនអីទៅមានតែប៉ុណ្ណឹងឯង
អត់ដឹងធ្វើអីទៀត។
ក៖ សម្រាប់អ៊ីស្រីៗ ចូលចិត្តមហូបអីខ្លាំងជាងគេ?
ខ៖ ខ្ញុំសម្លរកកូរ ស្លរប្រហើរ ស្លរកកូរនឹងឯង ចូលចិត្តហើយនឹងជំនាញ
ក្រៅពីនោះមិនសូវចង់ទេ ធម្មតាៗ។
ក៖ ទាក់ទងនឹងចម្រៀងអ៊ីស្រី ចូលចិត្តស្តាប់ចម្រៀងមេចដែរ?
ខ៖ បុរាណ ចូលចិត្តបុរាណៗ។
ក៖ ចូលចិត្តតារាបណាច្រៀង?
ខ៖ រកនឹកមិនឃើញទេ ដូចពួកណយវណ្ណេតអីពីដើមៗចូលចិត្តស្តាប់ណាស់
ផ្សេងៗមិនដឹងតួរស្អីខ្លះទេ អត់ដឹងទេ។
ក៖ ចុះពេលទំនេរ អ៊ីស្រីចូលចិត្តទៅលេងនៅឯណា?
ខ៖ ខ្ញុំអត់ដែរទៅណានូវតែផ្ទះ មិនដែលចង់ទៅណាទេ ចេញចូលៗ
នៅតែផ្ទះនោះឯង អត់ដែរចង់ទៅលេងឯណាទេ មួយឆាកជីវិតអត់អាលីង
អត់ចង់បណ្តោយ។
ក៖ អរគុណ អម្បាញ់មិញខ្ញុំបានជម្រាប់សួរទាក់ទងនឹងអ៊ីស្រីផ្ទាល់
ទាក់ទងនឹងប្រវត្តខ្លះអញ្ចឹងណាស់
អញ្ចឹងទាក់ទងនឹងក្រុមគ្រួសាររបស់អ៊ីស្រីទាំអស់ មានអ្នកចេះលេងឧបរ្យករណ៍
តន្រ្តីទេ?
ខ៖ អត់ អត់មាននរណាចេះលេងអីទេ។
ក៖ ពួកគាត់មានអ្នកវជធ្វើទេ?
ខ៖ ចាស?
ក៖ ធ្វើឧបរ្យករតន្រ្តី?
ខ៖ គាតមានណាសូវចេះ ទេកូនៗ ខ្ញុំ។
ក៖ ចុះបងប្អូនខាងឪពុកម្តាយចេះទេ?
ខ៖ អត់ដឹង ខ្ញុំអត់ដែលដឹងព្រោះគាត់ចាស់ៗអស់ហើយ។
ក៖ ផ្ទះរបស់អ៊ីស្រីធ្វើពីអ្វីដែរ?
ខ៖ ឈើ។
ក៖ សរសរធ្វើអំពីអ្វីដែរ?
ខ៖ ឈើ។
ក៖ ចុះតំបូលធ្វើពីអីដែរ?
ខ៖ ស័ង្កសី។
ក៖ ចុះជញ្ជាំងធ្វើពីអី?
ខ៖ ជញ្ជាំងក្តា។
ក៖ ចុះបង្អួចវិញ?
ខ៖ ឈើដែរ។
ក៖ របងជុំវិញផ្ទះអ៊ីស្រីធ្វើដាក់អីដែរ?
ខ៖ អត់មានស្អីទេ មានតែកូនដើមអំពិលកំប៉ិកកំប៉ុក ចាស អត់មានសរសរ
មានក្រាក់អីទេ មានតែដើមអំពិលដាំរាំងៗល្បែងអញ្ចឹងទៅ។
ក៖ អ៊ីស្រីបានជួយសាងសង់ ផ្ទះនោះទេ?
ខ៖ ចាស?
ក៖ ផ្ទះរបស់អ៊ីស្រី អ៊ីស្រីបានជួយសាងសង់ផ្ទះនោះទេ?
ខ៖ ចាស បានជួយតើ។
ក៖ ហើយផ្ទះនោះ ធ្វើដោយជាង ឬធ្វើខ្លួនឯង?
ខ៖ ធ្វើខ្លួនឯង។
ក៖ បានន័យថា ជាងធ្វើ ហើយអ៊ីប្រុសធ្វើដែរ?
ខ៖ ចាស ជាងនោះបងខ្ញុំធ្វើ បងទីបីធ្វើ ចាស ធ្វើខ្លួនឯងបងធ្វើអោយផ្ទាល់។

ក៖ បាទ អំបាញ់មិញ ខ្ញុំបានសួរទាក់ទងនឹងផ្ទះ និងទាក់ទងនឹងឧបរករណ៍តន្រ្តី ចង់សួរបន្ទាប់ទៅទៀត
ចង់សួរអ៊ីស្រីទាក់ទងនឹងជំនាញអ៊ីស្រីធ្លាប់តាំងពីក្មេងមកដល់ឥឡូវនេះ
តើអ៊ីស្រីធ្លាប់ អ៊ីស្រីមានចេះចំនាញមួយចំនួនដែរទេ ដូចជាជំនាញត្បាញរវៃ?
ខ៖ ខ្ញុំមិនសួរចេះអីទេ បើខាងលក់តវ៉ាន់ចេះ ខាងជំនាញត្បាញកន្ទេលអី ខ្ញុំអត់ចេះទេ។
ក៖ លក់តវ៉ាន់កំប៉ិកប៉ុកនោះលក់អីគេ?
ខ៖ បន្លែ ដូចជាត្រីអីសព្វគ្រប់ណាស់។
ក៖ អ៊ីស្រីលក់ពេញមួយថ្ងៃក៏លក់ពេលណាដែរ?
ខ៖
ម៉ោងប្រាំពីរដល់ម៉ោងដប់មួយមកវិញមានតែប៉ណ្ណឹងឯងមានបានចេញទៅណាឆ្ងាយ។
ក៖ អញ្ចឹងទាក់ទងនឹងដាំដំណាំអ៊ីស្រីចេះដាំដំណាំអីខ្លះ ដំណាំអីគេទៅអ៊ីស្រី?
ខ៖ ដាំត្រឡាច ដាំចេក ដាំដូងអីទៅ។
ក៖ ដាំត្រឡាច សម្រាប់លក់ ឬធ្វើម្ហូប?
ខ៖ ដម្រាប់លក់ខ្លះ និងធ្វើម្ហូបខ្លះទៅ ជួយបានលុយបានកាក់ចាយវាយលក់ទៅ យើងហូបនាំកូននាំចៅ ធ្វើបន្លែខ្លះទៅ។
ក៖ អ៊ីស្រីមានដីធំសម្រាប់ដាំដំណាំដែរទេ?
ខ៖ មានដីបន្តិចបន្តួចនេះឯង ដាំអីកំប៉ិកកំប៉ុកក្នុងផ្ទះណាស់
ខ្ញុំមិនដែលមានដីធំនឹងគេទេ មានតែបន្តិចបន្តួចនឹងឯង។
ក៖ អ៊ីស្រីចេះធ្វើត្នោត យកស្ករទេ?
ខ៖ ខ្ញុំអត់ចេះទេ ចេះតែឪ ពីដើមឪខ្ញុំគាត់ឡើងត្នោតដែរ គាត់ឡើងត្នោដែរ ដល់ពេលគាត់ចាស់គាត់ឈប់ទៅ។
ក៖ គាត់ឡើងត្នោតដើម្បីធធ្វើស្ករ?
ខ៖ ចាស ធ្វើស្ករ បានលក់ បានលុយ បានអីខ្លះទៅ
ចាស់ទៅគាត់ឈប់ឡើងឈប់អីទៅ។
ក៖ អញ្ចឹងទាក់ទងនឹងក្រុមគ្រួសាររបស់អ៊ីស្រី មានអ្នកចេះធ្វើកន្រ្ទកទេ?
ខ៖ អត់ទេ។
ក៖ ចុះទាក់ទងនឹងបង្គីអីមានអ្នកចេះទេ?
ខ៖ អត់ទេ។
ក៖ អញ្ចឹងទាក់ទងនឹងការដាំត្រឡាច ដាំបន្លែសម្រាប់លក់ដូរ
ដោយសារអ៊ីស្រីចូលចិត្តលក់ដូរ តើអ៊ីស្រីដាំខ្លួនឯងយកទៅលក់ ឬទិញគេយកទៅលក់?
ខ៖ ទិញរបស់គេខ្លះ យើងបានរបស់យើងខ្លះ។
ក៖ ពេលលក់ លក់ម៉ាព្រឹកៗ ទេ?
ខ៖ លក់ម៉ាព្រឹកទេ ពេលងថ្ងៃយើងកូន មើលចៅ។
ក៖ សួរបន្តិចទៀត ទាក់ទងនឹងបទពិសោធន៍របស់អ៊ីស្រីតាំងពីក្មេងមក
បទពិសោធន៍ល្អបំផុតសប្បាយបំផុតនៅក្នុងចិត្តអ៊ីស្រីពេលណាដែរ?
ខ៖ ពេលសប្បាយក្នុងឆាកជីវិត ពេលក្រុមគ្រួសារគ្មានបញ្ហា សប្បាយចិត្តខ្លួនឯង មិនមានអ្នកណាអ្វីអោយកើតទុកអីទេ
សប្បាយអញ្ចឹងទៅមិនមានកើតទុកកើតអីទេ
ពេលកូនរករឿងអានឹងបានពិបាកចិត្ត ឥឡូវនេះអត់មានកើតទុកកើតអីទេ សប្បាយធម្មតា។
ក៖ អ៊ីស្រីថាបើអត់មានអ្នកធ្វើអោយពិបាកចិត្តគឺសប្បាយចិត្តហើយ។
ខ៖ សប្បាយចិត្តមួយជីវិត បើគ្មានអ្នករករឿង ពីនេះពីមោះមកក៏អត់ ពិបាកចិត្តដែរ ដល់ពេលអីឡូវអត់ដែលអីទេ សុខសាន្តរហូត។

ក៖ អ៊ំស្រីធ្លាប់មានបំណងចង់បានអ្វីកាលពីនៅក្មេង កាលពីនៅក្មេងប៉ុន
អាអូនកាលពីក្មេងធ្លាប់មានក្ដីសម័យដូចនេះទេ?
ខ៖ ខ្ញុំអត់មានចង់បានអីទេ ចង់បានរៀនអោយចេះដឹងនឹងគេ
ដល់ពេលចាយដន់ពេលឪពុកឈឺ ឪពុកខូចទៅ
ក៏បានរៀនត្រឹបថ្នាក់ទីបួនតែប៉ុណ្ណោះ ខ្ញុំអន់ចិត្តតាំងពីនោះរហូតមក
បានថាឥឡូវប្រដៅកូនចៅអោយខំរៀនសូត្រ ខំរៀនអោយចេះ
កំអោយល្ងង់ដូចខ្ញុំអញ្ចឹង ខ្ញុំចង់តែប៉ុណ្ណឹង មួយឆាកជីវិត បើល្ងង់ស្ដាយ។
ក៖ អញ្ចឹងមុននឹងបញ្ចប់ដូចខ្ញុំបានជម្រាប់អ៊ំស្រី តាមពិតខ្ញុំនិងជម្រាបឥឡូវនេះ
ខ្ញុំគឺជាម្នាក់ដែលទាក់ទងនឹងក្រុមការងារ
គម្រោងប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា
ដែលខ្ញុំបានជម្រាបខាងដើមខ្លះៗនោះ
គម្រោងដែលទាក់ទងនឹងប្រវត្តិប្រជាជនកម្ពុជានេះ
គម្រោងនេះត្រូវបានឧបត្ថម្ភដោយសកលវិទ្យាល័យប៊ីវ៉ាយយូរសហរដ្ឋអាមេរិច
បើសិនជាអ៊ំស្រីចង់ស្វែងរកពត៍មានដែលទាក់ទងនឹងអ៊ំស្រីផ្ទាល់
អ៊ំស្រីអាចទាក់ទងទៅកាន់វេបសាយ cambodianoralhistories.byu.edu
អញ្ចឹងគោលបំណងរបស់អង្គការនេះគឺដើម្បីរក្សាពត៍មានរបស់អ៊ំស្រី ទាំងរូបថត
ទាំងសម្លេងរបស់អ៊ំស្រី
សម្រាប់ទុកអោយកូនចៅជំនាន់ក្រោយចង់ដឹងអ៊ំពីបទពិសោធន៍របស់អ៊ំស្រីផ្ទាល់
បាទហើយចំណុចមួយផ្សេងទៀតគឺដើម្បីអោយពួកខ្ញុំទាំងអស់គ្នាបានរៀនសូត្រ
ហើយដឹងថាអ៊ំស្រីមានបទពិសោធន៍អ្វីខ្លះនៅក្នុងជីវិត
មានបងប្អូនប៉ុន្មានអ្នកដូចជាអ្វីដែលខ្ញុំបានជម្រាបសួរអ៊ំស្រីតាំងពីដើមរហូតដ
ល់ចប់ បាទអញ្ចឹងជាចុងក្រោយ អ៊ំស្រីមានយោបល់
ឬក៏មតិយោបល់យ៉ាងណាសម្រាប់ក្មេងៗ ជំនាន់ក្រោយ
ដោយសារអ៊ំស្រីបានជំរាបថា ចង់អោយកូនចៅបានរៀនសូត្រ
អ៊ំស្រីក៏ធ្លាប់មានគោលបំណងមួយដែរថា ចង់រៀនសូត្រអោយបានខ្ពង់ខ្ពស់
មកដល់កន្លែងនេះធអ៊ំស្រីចង់ផ្ដែផ្ដាំអ្វីទុកអោយកូនចៅជំនាន់ក្រោយដើម្បីអោ
យគាត់កាន់តែល្អប្រសើរថែមទៀត?
ខ៖ ខ្ញុំគ្មានយោបល់អីទេ គ្រាន់តែចង់ផ្ដាំផ្ញើរអោយកូនចៅជំនាន់ក្រោយ
កូនចៅខំរៀន ការចេះដឹងនឹងគេ រកស៊ីទៅមុខទៅក្រោយ
ជំនាន់មុនជំនាន់ក្រោយ អោយចៅៗ កូនៗ
រៀនសូត្រចេះដឹងកំអោយល្ងិតល្ងង់ដូចខ្ញុំទៀត តែប៉ុណ្ណឹង។
ក៖ បច្ចុប្បន្ននេះអ៊ំស្រីគិតថាវិស្ស័យដែលទាក់ទងនឹង
ឬក៏ការរកស៊ីអីដែលអ៊ំស្រីគិតថា ធ្វើអោយជីវិតរបស់គាត់រីកចំរើននោះណាស់?
ខ៖ ខ្ញុំមានគិតអីគិតថាកិច្ចការធ្វើចាំបាច់រាល់ថ្ងៃនេះណាស់
ទៅមុខទៅជារៀងរាល់ថ្ងៃទៅ
កុំអោយើងឡេះឡោះដើរទៅលិចដើរទៅកើតចង់អោយរករហូត
អោយបានមាននឹងគេទៅ។
ក៖ បានន័យថាគាត់ត្រូវព្យាយាមប្រឹងប្រែងរហូតត្រូវទេ?
ខ៖ ចាស ព្យាយាមប្រឹងប្រែងខំរិះរកទៅ អោយបានទៅមុខទៀត
កំអោយលំបាកវេទនាណាស់ចង់អោយចៅរៀនអោយបានចេះដឹងតែប៉ុណ្ណឹង។
ក៖ អញ្ចឹង អ៊ំស្រីមានអីបន្ថែមទៀតទេ?
ខ៖ អស់ហើរមានតែប៉ុណ្ណឹងឯង។
ក៖ អញ្ចឹងអរគុណណាស់អ៊ំស្រី។